**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៣៧/សសរ**

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ស្ដីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ និងឆ្លើយតបការឆ្លងរាលដាលជាអន្តរជាតិនៃជំងឺនៅតាមច្រកចេញ-ចូល
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ស្ដីពីការកែសម្រួលមាត្រា៨ នៃអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ស្ដីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់និងឆ្លើយតបការឆ្លងរីករាលដាលជាអន្តរជាតិនៃជំងឺនៅតាមច្រកចេញ-ចូល
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ស្ដីពីវិធានការចត្តាឡីស័ក ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្ដីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញសេចក្ដីសម្រេចលេខ ២៩ សសរ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ ស្ដីពីការបង្កើតគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ (COVID-19)
- បានឃើញសេចក្ដីសម្រេចលេខ ២៦ សសរ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ (COVID-19)

- បានឃើញសេចក្តីសម្រេចលេខ ៣៤ សសរ ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០២០ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ (COVID-19)
- បានឃើញសេចក្តីសម្រេចលេខ ០៦០ សខល ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការបង្កើតអនុគណៈកម្មការគ្រប់គ្រងសន្តិសុខ និងសណ្តាប់ធ្នាប់នៅតាមគោលដៅ និងតំបន់ចត្តាឡីស័កដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ (COVID-19)
- យោងតាមសំណូមពរចាំបាច់នៃការងារ

## សម្រេច

**ប្រការ១**.-

ត្រូវបានបង្កើត**គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស** ដែលមានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| ១. លោកជំទាវវេជ្ជបណ្ឌិត **ឱ វណ្ណឌីន** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | ប្រធាន |
| ២. ឯកឧត្តមសាស្ត្រាចារ្យ **ហ៊ុន ចំរើន** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| ៣. ឯកឧត្តមវេជ្ជបណ្ឌិត **ឡូ វាសនាគិរី** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| ៤. ឯកឧត្តមវេជ្ជបណ្ឌិត **ម៉ុម កាង** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| ៥. លោកជំទាវ **គឹម សេដ្ឋានី** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៦. ឯកឧត្តម **ហេង សួរ** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៧. ឯកឧត្តម **គុយ ពុំ** | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | អនុប្រធាន |
| ៨. ឯកឧត្តមនាយឧត្តមសេនីយ៍ **សម តារា** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៩. ឯកឧត្តមនាយឧត្តមសេនីយ៍ **ឥត សារ៉ាត់** | អគ្គមេបញ្ជាការរង និងជានាយសេនាធិការចម្រុះនៃកងយោធពលខេមរភូមិន្ទ | អនុប្រធាន |
| ១០. ឯកឧត្តមវេជ្ជបណ្ឌិត **ស៊ិត មិណ្ណា** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១១. ឯកឧត្តមវេជ្ជបណ្ឌិត **ស្រុយ សេដុល្លា** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | លេខាធិការ |
| ១២. ឯកឧត្តមឱសថការី **ឈី ហុង** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | លេខាធិការ |
| ១៣. ឯកឧត្តមវេជ្ជបណ្ឌិត **ម៉ុង វណ្ណារុំ** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១៤. ឯកឧត្តមឱសថការី **ឆាន មុន្នា** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១៥. ឯកឧត្តម ប្រាក់ **ចូនហុង** | អគ្គលេខាធិការនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៦. ឯកឧត្តមវេជ្ជបណ្ឌិត **ហុក គឹមចេង** | អគ្គនាយកបច្ចេកទេសសុខាភិបាល | សមាជិក |
| ១៧. ឯកឧត្តម **សុខ សំណេង** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ១៨. ឯកឧត្តម **យឹម ធុន្នី** | អគ្គនាយកនៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា | សមាជិក |
| ១៩. ឯកឧត្តម **ស្រី ធុន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២០. ឯកឧត្តមសាស្ត្រាចារ្យ **គង់ សល្យា** | អគ្គនាយករងមន្ទីរពេទ្យកាល់ម៉ែត | សមាជិក |
| ២១. ឯកឧត្តមសាស្ត្រាចារ្យ **ឌី រ៉េង** | នាយកមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត | សមាជិក |

| | | |
|---|---|---|
| ២២. ឯកឧត្តមសាស្ត្រាចារ្យ **ឈា ឆនណ្ណា** | នាយកវិទ្យាស្ថានជាតិសុខភាពសាធារណៈ | សមាជិក |
| ២៣. ឯកឧត្តមសាស្ត្រាចារ្យ **លុ លីឃាង** | នាយកមន្ទីរពេទ្យព្រះអង្គឌួង | សមាជិក |
| ២៤. ឯកឧត្តមសាស្ត្រាចារ្យ **តាន់ សុគុន** | នាយកមន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិន ព្រះកុសុមៈ | សមាជិក |
| ២៥. ឯកឧត្តមវេជ្ជបណ្ឌិត **ស៊ុង ទិនគ:** | ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២៦. ឯកឧត្តម លោកជំទាវ **អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ទាំង២៥** | | សមាជិក |
| ២៧. ឯកឧត្តម លោកជំទាវ **ប្រធានមន្ទីរសុខាភិបាលរាជធានី-ខេត្ត ទាំង២៥** | | សមាជិក |
| ២៨. លោកវេជ្ជបណ្ឌិត **សុខ ស្រ៊ុន** | ប្រធាននាយកដ្ឋានមន្ទីរពេទ្យ | សមាជិក |
| ២៩. លោកវេជ្ជបណ្ឌិត **ឈិត សុផល** | ប្រធាននាយកដ្ឋានសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀន | សមាជិក |
| ៣០.លោកឱសថការី **ថន ខៃលី** | ប្រធានឃ្លាំងឱសថកណ្តាល | សមាជិក |
| ៣១. លោកស្រីវេជ្ជបណ្ឌិត **គីម រតនា** | ប្រធានមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក | សមាជិក |
| ៣២. លោកសាស្ត្រាចារ្យ **ញឹម អង្គារមុស្ស** | នាយកមន្ទីរពេទ្យកុមារជាតិ | សមាជិក |
| ៣៣.លោកវេជ្ជបណ្ឌិត **លី ចិដ្ឋារ៉ាឌុច** | អនុប្រធាននាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល | សមាជិក |
| ៣៤.លោកឱសថការី **ហួត សេងផុង** | អនុប្រធាននាយកដ្ឋានឱសថ ចំណីអាហារគ្រឿងសម្អាង និងបរិក្ខារពេទ្យ | សមាជិក |
| ៣៥. លោកស្រីវេជ្ជបណ្ឌិត **តេង ស្រី** | អនុប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង | សមាជិក |
| ៣៦. លោកឱសថការី **ឱក ចិជិត** | អនុប្រធានមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក | ជំនួយការ |
| ៣៧. លោកស្រីឱសថការី **ម៉ា ពុធនាថ** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | ជំនួយការ |
| ៣៨. លោកជំទាវបណ្ឌិត **ពេជ្រ ចន្ទមុនី ហ៊ុនម៉ាណែត** | អនុប្រធានក្រុមប្រឹក្សាភិបាលសមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ(TYDA) | សមាជិក |
| ៣៩. លោក **ហោ សេរីវឌ្ឍន៍** | អនុប្រធានសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា | សមាជិក |
| ៤០. លោកឱសថការី **សៀ ផុល** | អនុប្រធាននាយកដ្ឋានឱសថ ចំណីអាហារបរិក្ខារពេទ្យ និងគ្រឿងសំអាង | សមាជិក |
| ៤១. លោក **ខៀវ ហេង** | ព្រឹទ្ធបុរសរងមហាវិទ្យាល័យអគ្គិសនី និងអេឡិកត្រូនិកនិងជាប្រធានដេប៉ាតឺម៉ង់ព័ត៌មានវិទ្យានៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (តិចណូ) | សមាជិក |
| ៤២. លោក **ខៀម សំណាង** | ប្រធានការិយាល័យព័ត៌មានវិទ្យានៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (តិចណូ) | សមាជិក |
| ៤៣. លោកវេជ្ជបណ្ឌិត **លាង រិទ្ធា** | ប្រធានកម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម | សមាជិក |
| ៤៤. លោកឱសថការី **ហៀង គីមសៀត** | ប្រធានការិយាល័យនិយ័តកម្មឱសថនៃនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង | សមាជិក |
| ៤៥. លោក **សៀង ចំរើន** | អនុប្រធានការិយាល័យព័ត៌មានវិទ្យានៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (តិចណូ) | សមាជិក |
| ៤៦. លោក **ស្រេង ផេង** | មន្ត្រីអគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល | សមាជិក |

៤៧. កញ្ញា **អ៊ិន ច័ន្ទអញ្ញា** ជំនួយការរដ្ឋលេខាធិការ សមាជិក

**ប្រការ២.-**

គណៈកម្មការនេះ មានតួនាទី និងភារកិច្ច ដូចតទៅ ៖

- គ្រប់គ្រងដឹកនាំ ចាត់ចែង ការងារចាក់វ៉ាក់សាំងកូវីដ-១៩ នៅក្នុងក្របខណ្ឌទូទាំងប្រទេស
- ពិនិត្យរៀបចំផែនការចាក់វ៉ាក់សាំងកូវីដ-១៩ នៅទូទាំងប្រទេស
- បណ្តុះបណ្តាលក្រុមគ្រូពេទ្យ សម្រាប់បម្រើការងារចាក់វ៉ាក់សាំងកូវីដ-១៩
- បែងចែកវ៉ាក់សាំងកូវីដ-១៩ ទៅតាមទីកន្លែងចាក់វ៉ាក់សាំងនៅក្នុងក្របខណ្ឌទូទាំងប្រទេស
- ផ្គត់ផ្គង់ ថវិកា សម្ភារៈ បរិក្ខារចាំបាច់ សម្រាប់បម្រើការងារចាក់វ៉ាក់សាំងកូវីដ-១៩
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃពីវឌ្ឍនភាពនៃការចាក់វ៉ាក់សាំងកូវីដ-១៩ នៅទូទាំងប្រទេស
- សម្របសម្រួលកិច្ចការចាក់វ៉ាក់សាំង និងការងារពាក់ព័ន្ធ
- សម្របសម្រួលជាមួយដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ ព្រមទាំងអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងបណ្តាស្ថានទូតនានាប្រចាំកម្ពុជា លើការងារចាក់វ៉ាក់សាំងកូវីដ-១៩
- រៀបចំប្រព័ន្ធរបាយការណ៍ និងរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល
- កិច្ចការផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការងារចាក់វ៉ាក់សាំងកូវីដ-១៩។

**ប្រការ៣.-**

- គណៈកម្មការនេះ មានសិទ្ធិរៀបចំអនុគណៈកម្មការចំពោះកិច្ច និងលេខាធិការដ្ឋាន សម្រាប់គាំទ្រដំណើរការនៃគណៈកម្មការចំពោះកិច្ចនេះ និងអាចស្នើសុំបន្ថែមនូវសមាជិក-សមាជិកា ទៅតាមការចាំបាច់។
- សមាជិកទាំងអស់នៃគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេសត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន និងអនុវត្តភារកិច្ចទៅតាមការចាត់ចែងរបស់ប្រធាន។

**ប្រការ៤.-**

- គណៈកម្មការចំពោះកិច្ចនេះ អាចអញ្ជើញដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ ព្រមទាំងអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងបណ្តាស្ថានទូតនានាប្រចាំកម្ពុជា លើការងារចាក់វ៉ាក់សាំង ចូលរួមប្រជុំ និងប្រឹក្សាយោបល់ ទៅតាមតម្រូវការចាំបាច់។
- គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសុខាភិបាល។
- នៅតាមក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត ត្រូវរៀបចំអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ដែលទទួលខុសត្រូវលើសម្រង់ស្ថិតិអ្នកស្ម័គ្រចិត្តចាក់វ៉ាក់សាំងកូវីដ-១៩ ក្រោមសមត្ថកិច្ចរបស់ខ្លួន និងការងារប្រតិបត្តិការចាក់វ៉ាក់សាំង នៅតាមក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត អនុលោមទៅតាមការសម្រេចរបស់គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស ព្រមទាំងតាមដាន និងរាយការណ៍វឌ្ឍនភាពការងារចាក់វ៉ាក់សាំងជាប្រចាំថ្ងៃ ជូនគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ឱ្យបានទៀងទាត់។

**ប្រការ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៤ កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ